Food and Agriculture Organization of the United Nations

សូមធ្វើសកម្មភាពឥឡូវនេះ

គម្រោង "គាំទ្រការអនុវត្តក្របខណ្ឌគតិយុត្តកូដិចស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ CODEX AMR TEXTS (ACT)"

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) តាមរយៈចំណីអាហារ គឺជាការគំរាមកំហែងជាសកល។ យើងគ្មានពេលត្រូវរង់ចាំនោះឡើយ។

តើគម្រោង ACT ធ្វើអ្វីខ្លះ

គម្រោង ACT អនុវត្តសកម្មភាពនៅទូទាំងសកលលោក និងនៅតាមប្រទេសនានា ដើម្បីឆ្លើយតបចំពោះបញ្ហាភាពស៊ាំនឹងឱសថប្រឆាំងមេរោគ កើតចេញពីចំណីអាហារ តាមរយៈការអនុវត្តក្របខណ្ឌគតិយុត្តកូដិចស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ **ប្រទេសបូលីវី (រដ្ឋពហុជាតិសាសន៍) មាន ប្រទេសកម្ពុជា កូឡុំប៊ី ម៉ុងហ្គោលី នេប៉ាល់ និងប៉ាគីស្ថាន**។

ក្របខណ្ឌគតិយុត្តកូដិចស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ(បទដ្ឋានអន្តរជាតិ គោលការណ៍ណែនាំ និងក្រមអនុវត្ត) ដាក់ចេញនូវជំហាន និងគោលនយោបាយដែលអ្នកធ្វើសេចក្តីសម្រេចគួរចាត់វិធានការ ការពារសុខភាពអ្នកប្រើប្រាស់ និងធានាឱ្យមានការអនុវត្តឱ្យបានត្រឹមត្រូវ ក្នុងការធ្វើជំនួញជួញដូរចំណីអាហារ។

ការគ្រប់គ្រងអោយបានល្អប្រសើរនូវភាពស៊ាំនឹងឱសថប្រឆាំងមេរោគកើតចេញពីចំណីអាហារអោចសម្រេចទៅបាន តាមរយៈសកម្មភាព ដូចរៀបរាប់នៅក្នុងក្របខណ្ឌគតិយុត្តកូដិចស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនេះ ។

បង្កើនការយល់ដឹងអំពីក្របខណ្ឌគតិយុត្តកូដិច ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើភាពស៊ាំនឹងឱសថប្រឆាំងមេរោគកើតចេញពីចំណីអាហារ។

ផ្តល់ការគាំទ្រដល់ការប្រមូល និងការវិភាគទិន្នន័យ ដើម្បីពង្រឹងការតាមដាន និងសង្កេតឃ្លាំមើលភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ជួយដល់បណ្តាប្រទេសនានា ក្នុងការវាយតម្លៃលើតម្រូវការនានា និងយកអនុវត្តឧត្តមានុវត្តន៍ ដើម្បីកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ តាមរយៈចំណីអាហារ។

សូមធ្វើសកម្មភាពឥឡូវនេះ

- រៀងរាល់ឆ្នាំនៅទូទាំងសកលលោកចំណីអាហារដែលពុំមានសុវត្ថិភាពបង្កឱ្យមានជំងឺឆ្លងតាមចំណីអាហារ **ចំនួន ៦០០ លាន ករណី** និងការបាត់បង់ជីវិត ចំនួន ៤២០ ០០០ ករណី។ យោងតាមរបាយការណ៍ WHO. 2015.
- **ការឆ្លង មេរោគក្នុងចំណីអាហារ បណ្តាលមកពីបាក់តេរីស៊ាំនឹង**ឱសថប្រឆាំងមេរោគ គេឃើញកើតមានជាទូទៅ។ យោងតាមអត្ថបទ Foods. 2022.
- ការឆ្លងមេរោគអាចពិបាកព្យាបាល និងពេលខ្លះមិនអាចព្យាបាលបានតែម្តង។ ឧទាហរណ៍ជារៀងរាល់ឆ្នាំ នៅទូទាំងសកលលោកមានមនុស្សជាង **៥ ០០០ នាក់បាត់បង់ជីវិត** ដោយសារតែការឆ្លងជំងឺសាំម៉ូណេឡា ដែលមិនមែនជាប្រភេទជំងឺគ្រុនពោះវៀនដែលស៊ាំនឹងឱសថប្រឆាំងមេរោគ។ យោងតាមអត្ថបទ The Lancet. 2019.
- នៅទូទាំងសកលលោក ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាផលវិបាកដែលកើតឡើងដោយសារការប្រើប្រាស់ ជាពិសេស **ការប្រើលើសកម្រិត និងការប្រើប្រាស់មិនត្រឹមត្រូវ** នៃប្រភេទឱសថប្រឆាំងមេរោគលើមនុស្ស រុក្ខជាតិ និងសត្វ។ យោងតាមផែនការសកម្មភាពស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ FAO. 2021.
- **សកម្មភាពនានា** ដើម្បីបង្កើនការយល់ដឹង នៅតាមបណ្តាប្រទេសដែលមានប្រាក់ចំណូលទាប និងលមធ្យម អំពីហានិភ័យនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគក្នុងប្រព័ន្ធស្បៀងកសិកម្ម **លែងជាសកម្មភាពដែលកើតមានជាទូទៅទៀតហើយ។ យោងតាមការបោះពុម្ពផ្សាយ** WHO. 2021.

សូមធ្វើសកម្មភាពឥឡូវនេះ។ ធ្វើសកម្មភាពអ្វីដែលអ្នកអាចធ្វើបាន

ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាការរាតត្បាតជាសកលដែលកើតឡើងយ៉ាងស្ងាត់ៗ ហើយ 'យើងទាំងអស់គ្នាចាំបាច់ត្រូវពូតដៃគ្នា' ដើម្បីឆ្លើយតបចំពោះការរាតត្បាតជាសកលនេះ។

និងអ្នកកែច្នៃចំណីអាហារ

- បង្កើនការយល់ដឹងអំពីភាពចាំបាច់ក្នុងការឆ្លើយតបនឹង ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ កើតចេញពីចំណីអាហារ និងឯកសារច្បាប់នានាដែលអាចយកមកប្រើប្រាស់បាន ដូចជា ក្របខណ្ឌណាគតិយុត្តកូដិចស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនេះ។
- រៀបចំនិងពង្រឹងការអនុវត្តបទបញ្ជានានាដើម្បីជំរុញឱ្យមានការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយទំនួលខុសត្រូវ និងដោយប្រុងប្រយ័ត្ន។
- ពង្រឹងសមត្ថភាពពិនិត្យតាមដាន និងការឃ្លាំមើលភាពស៊ាំនឹងឱសថប្រឆាំងមេរោគ និងការប្រើប្រាស់សារធាតុប្រឆាំងមេរោគក្នុងចំណីអាហារ និងក្នុងប្រព័ន្ធស្បៀងដើម្បីផ្តល់ព័ត៌មានឱ្យបានកាន់តែប្រសើរអំពីសកម្មភាពគ្រប់គ្រងក្នុងការកាត់បន្ថយភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។
- ជំរុញឱ្យមានការអនុវត្តល្អប្រសើរក្នុងការទប់ស្កាត់ភាពស៊ាំនឹងឱសថប្រឆាំងមេរោគកើតចេញពីចំណីអាហារ ដោយសង្កត់ធ្ងន់លការបញ្ឈប់ការប្រើប្រាស់សារធាតុប្រឆាំងមេរោគធ្វើជាសារធាតុជំរុញការលូតលាស់ ។

អ្នកផលិត និងអ្នកកែច្នៃចំណីអាហារ

- ឈ្វេងយល់ថាតើការប្រើប្រាស់សារធាតុប្រឆាំងមេរោគដោយប្រុងប្រយ័ត្នអាចជួយឱ្យសត្វកាន់តែមានសុខភាពមាំមួន លើកកម្ពស់សុវត្ថិភាពចំណីអាហារ និងផលសេដ្ឋកិច្ចដោយរបៀបណា។
- ពិគ្រោះយោបល់ជាមួយនឹងបសុពេទ្យ ឬអ្នកជំនាញខាងសុខភាពសត្វ និងដំណាំ ដើម្បីធ្វើការកំណត់ ថាតើសារធាតុប្រឆាំងមេរោគគឺជាថ្នាំព្យាបាលជំងឺសត្វ និងរុក្ខជាតិ/ដំណាំ ដែលមានប្រសិទ្ធភាពបំផុតដែឬទេ។
- រក្សាទុកកំណត់ត្រាអំពីការប្រើប្រាស់សារធាតុប្រឆាំងមេរោគ ។
- អនុវត្តតាមឧត្តមានុវត្តន៍ ដើម្បីបង្ការជំងឺ និងបង្កើនផលិតកម្មដោយមិនចាំបាច់ប្រើប្រាស់សារធាតុប្រឆាំងមេរោគ។

អ្នកជំនាញផ្នែកសុខភាព (សត្វ និងរុក្ខជាត/ដំណាំ)

- ទទួលស្គាល់ថាការប្រើប្រាស់សារធាតុប្រឆាំងមេរោគ អាចបង្កផលវិបាកនាំឱ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ កើតចេញពីចំណីអាហារ សុវត្ថិភាពអាហារ សុខភាពមនុស្ស និងបរិស្ថាន។
- ចេញតែវេជ្ជបញ្ជា និងប្រើប្រាស់ឱសថប្រឆាំងមេរោគ ស្របតាមបទបញ្ជាពាក់ព័ន្ធនានា នៅពេលដែលគ្មានជម្រើសផ្សេងទៀត។
- គាំទ្រដល់ប្រព័ន្ធតាមដាន និងឃ្លាំមើលនៅថ្នាក់ជាតិ តាមរយៈការប្រមូល និងរាយការណ៍ពីទិន្នន័យនានានៅក្នុងប្រព័ន្ធស្បៀងកសិកម្ម។

អ្នកប្រើប្រាស់

- តស៊ូមតិឱ្យមានគោលនយោបាយដែលលើកកម្ពស់ការប្រើប្រាស់ឱសថប្រឆាំងមេរោគប្រកបដោយទំនួលខុសត្រូវ និងប្រុងប្រយ័ត្ន។
- គាំទ្រដល់អ្នកផលិតស្បៀងទាំងឡាយណាដែលអនុវត្តន៍តាមការអនុវត្តល្អប្រសើរពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុប្រឆាំងមេរោគតាមរយៈការទិញផលិតផលរបស់ពួកគេ។
- ការពារខ្លួនឯងពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ កើតចេញពីចំណីអាហារ តាមរយៈការទុកដាក់អាហារឱ្យមានសុវត្ថិភាព (អនុវត្តន៍អនាម័យខ្លួនប្រាណឲ្យបានល្អ រៀបចំ និងសម្អាតទីកន្លែង រៀបចំ និងទុកដាក់អាហារឱ្យស្អាតបានស្អាតល្អ បែងចែកថាផលិតផលឆៅ និងចម្អិនហើយ ចម្អិនអាហារឱ្យបានឆ្អិនល្អ រក្សាទុកអាហារនៅសីតុណ្ហភាពដែលមានសុវត្ថិភាព និងប្រើប្រាស់ គ្រឿងផ្សំឆៅដែលមានសុវត្ថិភាព)។

សម្រាប់ព័ត៌មានបន្ថែមសូមចូលមើល៖

សូមចូលរួមនៅក្នុងការសន្ទនា
#AMRCodexTexts

ផ្តល់ថវិកាគាំទ្រដោយ
ក្រសួងសុវត្ថិភាព
ចំណីអាហារ និងឱសថ
សាធារណរដ្ឋកូរ៉េ

Some rights reserved. This work is available under a CC BY-NC-SA 3.0 IGO licence

© FAO, 2024
CC6242KM/1/07.24